**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

លេខ: ៨៦៦ សហវ.ប្រក.

រាជធានីភ្នំពេញ,ថ្ងៃទី ២៣ ខែ វិច្ឆិកា ឆ្នាំ២០០១

# ប្រកាស
## ស្តីពី
## ការអនុវត្តន៍អាករបន្ថែមលើពន្ធគយ នៃផលិតផលប្រេងកាត

- បានឃើញ រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រឹត្យលេខ នស / រកត / ១១៩៨ / ៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញ ព្រះរាជក្រមលេខ ០២/ នស/ ៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញ ព្រះរាជក្រមលេខ នស / រកម / ០១៩៦ / ១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ អនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញ ព្រះរាជក្រមលេខ នរ/ រកម/ ០១.៩៩/ ០១ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ១៩៩៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីហិរញ្ញវត្ថុសំរាប់ការគ្រប់គ្រងឆ្នាំ១៩៩៩
- បានឃើញ សារាចររបស់រាជរដ្ឋាភិបាលលេខ ០៦.សរ ចុះថ្ងៃទី ១១ ខែ មិថុនា ឆ្នាំ១៩៩៩ ស្តីពីវិធានការបង្កើនប្រសិទ្ធភាពក្នុងការគ្រប់គ្រង និងការកែទំរង់សេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ
- បានឃើញ ចំណារសម្តេចនាយករដ្ឋមន្ត្រី ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ២០០១ លើលិខិតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លេខ ៥៤១៨ សហវ ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ២០០១
- យោងតាមសំណូមពរការងារចាំបាច់ក្នុងការបង្កើនប្រសិទ្ធភាពនៃការប្រមូលចំណូលពន្ធអាករ

## សំរេច

ប្រការ ១ : ត្រូវបានដាក់ឱ្យអនុវត្ត ចាប់ពីថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០២ តទៅ នូវអាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាតតាមអត្រាប្រាក់រៀលស្មើនឹង ពីរសេន ដុល្លារអាមេរិក សំរាប់ប្រេងសាំងប្រភេទE.A មួយលីត្រ និង បួនសេន ដុល្លារអាមេរិក សំរាប់ប្រេងម៉ាស៊ូត មួយលីត្រ ។

**ប្រការ ២ :** អាករបន្ថែមនៃពន្ធគយលើផលិតផលប្រេងកាតនេះ ត្រូវបានគ្រប់គ្រង និងប្រមូលនៅតាមមាត់ច្រកនាំចូល ព្រះរាជាណាចក្រកម្ពុជា នាពេលនាំចូលដោយ ទីចាត់ការគយនិងរដ្ឋាករ ក្នុងលក្ខខ័ណ្ឌ និងបទបញ្ញត្តិដូចគ្នានឹងការប្រមូលកំរៃយកមុន នៃផលិតផលប្រេងកាត ( RPP )។

**ប្រការ ៣ :** ចំណូលដែលទីចាត់ការគយនិងរដ្ឋាករប្រមូលបានពីអាករបន្ថែម នៃពន្ធគយ លើផលិតផលប្រេងកាតនេះ ត្រូវកត់ត្រាចូលខ្ទង់ចំណូលតាមនាមវលីថវិកា លេខ ១៣.០១.០៥ស្តីពីអាករបន្ថែមនៃពន្ធគយ លើផលិតផលប្រេងកាត ។

**ប្រការ ៤ :** ចំពោះទំនិញដូចមានចែងខាងលើនេះ ដែលបាននាំចូល និងបានធ្វើបែបបទនៃការមកដល់មុនថ្ងៃទី ០១ ខែ មករា ឆ្នាំ២០០២ ប៉ុន្តែមិនទាន់បានបំពេញបែបបទបង់ ឬ ប្រមូលពន្ធ អាករ និងកំរៃនានា នឹងពុំត្រូវបានអនុវត្តការប្រមូលអាករបន្ថែមនៃពន្ធគយ លើផលិតផលប្រេងកាតនេះឡើយ ។

**ប្រការ ៥ :** បទបញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៦ :** ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជា នាយកទីចាត់ការគយនិងរដ្ឋាករ អគ្គលេខាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានពន្ធដារ ប្រធានរតនាគារជាតិ ព្រមទាំងប្រធានអង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គាត ឈន់

<u>**ចម្លងជូន**</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី ( ដើម្បីជូនជាពត៌មាន )
- សភាពាណិជ្ជកម្ម ( ដើម្បីសហការផ្សព្វផ្សាយនិងអនុវត្ត )
- ឯកសារ-កាលប្បវត្តិ